# សេចក្តីថ្លែងការណ៍រួម

*រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦*

## នៅក្នុងឱកាសនៃទិវាអន្តរជាតិប្រឆាំងការរើសអើងទៅលើអ្នកស្រលាញ់ភេទដូចគ្នាឆ្នាំ ២០១៦ នេះ អង្គការសង្គមស៊ីវិល និងក្រុមហ៊ុនអាជីវកម្មស្នើឱ្យមានសមភាពពេញលេញ សម្រាប់អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា

នៅក្នុងឱកាសនៃទិវាអន្តរជាតិប្រឆាំងការរើសអើងឆ្នាំ២០១៦នេះ យើងខ្ញុំជាអង្គការសង្គមស៊ីវិល និង ក្រុមហ៊ុនអាជីវកម្មដែលមានរាយនាមខាងក្រោម រួមជាមួយអង្គការមកពីមជ្ឈដ្ឋានផ្សេងទៀតនៅជុំវិញពិភព លោកចូលរួមទិវាអន្តរជាតិប្រឆាំងការរើសអើងទៅលើអ្នកស្រលាញ់ភេទដូចគ្នាឆ្នាំ២០១៦ នេះ ដើម្បីប្រារព្ធដល់ សិទ្ធិរបស់ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទនិងអ្នកប្តូរភេទ("អ្នកស្រឡាញ់ភេទ ដូចគ្នា")នៅក្នុងសង្គមកម្ពុជា។ នៅប្រទេសកម្ពុជា អង្គការសង្គមស៊ីវិលនិងរដ្ឋាភិបាលបានបោះជំហានឆ្ពោះទៅរ កភាពរីកចម្រើននៃសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា ហើយក្នុងនោះរាប់ទាំងការវិវឌ្ឍនាពេលថ្មីៗនេះផងដែរ។ ទោះជាយ៉ាងណា នៅមានការងារសំខាន់ៗមួយចំនួនទៀតដែលចាំបាច់ត្រូវធ្វើដើម្បីធានាឱ្យមានសមភាព សម្រាប់ពលរដ្ឋគ្រប់រូប។ ប្រធានបទនៃទិវាអន្តរជាតិប្រឆាំងទៅនឹងការរើសអើងលើអ្នកស្រឡាញ់ភេទដូចគ្នានៅ ឆ្នាំនេះគឺ "សុខភាពផ្លូវចិត្តនិងសុខមាលភាព" ដែលទាញចំណាប់អារម្មណ៍អំពីផលប៉ះពាល់ដែលបង្កមកពីការ រើសអើងនិងការមាក់ងាយទៅលើអ្នកស្រឡាញ់ភេទដូចគ្នា។

របាយការណ៍ស្រាវជ្រាវថ្មីមួយមានចំណងជើងថា *«គំនិត អាកប្បកិរិយា និង ឥរិយាបថទៅលើអ្នក ស្រលាញ់ភេទដូចគ្នានៅកម្ពុជា»* ដែលបានបោះពុម្ពផ្សាយដោយសហគមន៍ឥន្ទធនូកម្ពុជា និង ក្រុមហ៊ុនស្រាវ ជ្រាវទីផ្សារអន្តរជាតិកម្ពុជា បានបង្ហាញពីការយល់ឃើញក្នុងចំណោមអ្នកស្រលាញ់ភេទផ្ទុយ និងអ្នកស្រលាញ់ ភេទដូចគ្នា (ដែលចំនួនអ្នកតបបទសម្ភាសមានភាគរយរៀងគ្នា គឺ ៨៦% និង ៨២%) បានលើកឡើងថា បញ្ហា ដ៏ធំបំផុតដែលអ្នកស្រឡាញ់ភេទដូចគ្នាក្នុងប្រទេសកម្ពុជាកំពុងប្រឈម គឺការរើសអើងដោយផ្អែកលើអត្តសញ្ញា ណយេនឌ័ររបស់ពួកគេ។ មួយភាគបីនៃអ្នកស្រឡាញ់ភេទដូចគ្នាដែលបានស្ទង់មតិ បានរាយការណ៍ថាជាលទ្ធ ផលពួកគាត់មានការលំបាកក្នុងការផ្ចង់លើកិច្ចការអ្វីមួយ គេងមិនលក់និងបាត់បង់ក្តីសង្ឃឹម។ កត្តាទាំងនេះបាន បង្កមកពីការរើសអើងដ៏រាលដាលនៅក្នុងសង្គម ដែលបង្កើតឱ្យមានផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរដល់អ្នក ស្រលាញ់ភេទដូចគ្នាជាច្រើន។

មានភស្តុតាងបង្ហាញថាការរើសអើងលើអ្នកស្រឡាញ់ភេទដូចគ្នាផ្តើមចេញពីដំបូងផងដែរនៅតាម សាលារៀន។ របាយការណ៍ដែលចេញផ្សាយថ្មីៗនេះដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក")មាន ចំណងជើងថា *«ការសម្លុតអ្នកស្រឡាញ់ភេទដូចគ្នានៅតាមសាលារៀនក្នុងប្រទេសកម្ពុជា»* បង្ហាញថា ការគំរាម

កំហែងបង្កឡើងដោយមិត្តភក្តិនិងតួអង្គសំខាន់ៗ ក្នុងនោះរួមមានទាំងគ្រូបង្រៀននិងនគរបាល ធ្វើឱ្យសិស្សដែលជាអ្នកស្រឡាញ់ភេទដូចគ្នាជាច្រើននាក់សម្រេចចិត្តបោះបង់ចោលការសិក្សា។ ជាង៣ភាគកណ្តាលនៃអ្នកស្រឡាញ់ភេទដូចគ្នាដែលបានរាយការណ៍ថារងការសម្លុតនៅសាលារៀនរបស់ពួកគេនោះ បានរៀបរាប់ពីបទពិសោធន៍នៃការប៉ះទង្គិចផ្លូវអារម្មណ៍ ដោយ៨០%បានលើកឡើងថាធ្លាប់ទទួលរងការបាក់ទឹកចិត្ត"ម្តងម្កាល" "ញយដង"ឬ"ជាញឹកញាប់"។

យើងខ្ញុំសូមសាទរចំពោះសេចក្តីសម្រេចរបស់ក្រសួងព័ត៌មាន ដែលធ្វើការហាមប្រាមចំពោះការរើសអើងទៅលើអ្នកស្រលាញ់ភេទដូចគ្នាតាមប្រព័ន្ធផ្សព្វផ្សាយ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងអប់រំ យុវជននិងកីឡាក្នុងការបញ្ចូលការប្រើវាក្យសព្ទទាក់ទិនទៅនឹងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ ឬ ការបង្ហាញទំនោរយេនឌ័រក្នុងកម្មវិធីអប់រំ។ យើងខ្ញុំក៏សាទរផងដែរចំពោះការដាក់បញ្ចូលនូវបញ្ហាអ្នកស្រឡាញ់ភេទដូចគ្នាទៅក្នុងផែនការយុទ្ធសាស្រ្តសម្រាប់ឆ្នាំ២០១៤-២០១៨ របស់ក្រសួងកិច្ចការនារី។ ទាំងនេះជាការបោះជំហានឆ្ពោះទៅរកវប្បធម៌នៃការទទួលយក និងការយល់ដឹងពីបញ្ហារបស់អ្នកស្រលាញ់ភេទដូចគ្នា ដែលធ្វើដំណើរលើវិថីមួយឆ្ពោះទៅរកការកែលម្អស្ថានភាពរបស់អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា។ យើងខ្ញុំសូមស្នើដល់គ្រូបង្រៀនមេត្តាជួយផ្សព្វផ្សាយអំពីបញ្ហារបស់អ្នកស្រឡាញ់ភេទដូចគ្នា និងសូមធ្វើជាគំរូទៅដល់សិស្សដទៃទៀត។

ជាមួយគ្នានេះ កត្តាសំខាន់ដែលធ្វើឱ្យកម្ពុជារីកចម្រើនទៅបាននោះ លុះត្រាតែជាសង្គមមួយដែលមានការចូលរួម និងមិនមានការរើសអើងទៅលើអ្នកស្រឡាញ់ភេទដូចគ្នា ដែលជាក្តីបារម្ភចម្បងមួយនៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពរបស់អង្គការសហប្រជាជាតិសម្រាប់ឆ្នាំ២០១៥~២០៣០។ គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពមានគោលបំណងលុបបំបាត់អសមភាព និងភាពអយុត្តិធម៌ ព្រមទាំងមានគោលបំណងឱ្យមានការចូលរួម និងការអប់រំប្រកបដោយគុណភាព និងសមភាពសម្រាប់ពលរដ្ឋទាំងអស់គ្នា ដើម្បីលុបបំបាត់ភាពក្រីក្រគ្រប់រូបភាពនៅគ្រប់ទីកន្លែង។ របាយការណ៍នាពេលថ្មីៗនេះចេញផ្សាយដោយអង្គការអនាគតយុវជនកម្ពុជាអាស៊ាននិងអង្គការម៉ាយក្រូរ៉េនបូអន្តរជាតិ (Micro Rainbow International) មានចំណងជើងថា *«ភាពក្រីក្ររបស់អ្នកស្រឡាញ់ភេទដូចគ្នាក្នុងប្រទេសកម្ពុជា»* បង្ហាញពីវិធីសាស្រ្តដែលអាចធ្វើឲ្យអ្នកស្រឡាញ់ភេទដូចគ្នាចាកចេញពីភាពក្រីក្រ និងក្លាយជាសមាជិកចូលរួមចំណែកក្នុងសង្គម ដែលធ្វើឱ្យសង្គមកាន់តែឱ្យតម្លៃដល់ពួកគេ។ ម្យ៉ាងទៀតការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពមានសារៈសំខាន់ណាស់ ដែលជាទូទៅគ្មានពលរដ្ឋណាម្នាក់ត្រូវបានផាត់ចេញពីផ្នែកណាមួយនៃសង្គមឡើយ ហើយក្នុងរបាយការណ៍នោះក៏បានបង្ហាញពីរបៀបនៃការគាំទ្រដល់អ្នកស្រឡាញ់ភេទដូចគ្នា ក្នុងការបង្កើតអាជីវកម្មខ្នាតតូចនិងការបណ្តុះបណ្តាលពួកគេ ដែលជាសកម្មភាពជាក់លាក់មួយដែលនឹងចូលរួមចំណែកដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព «ដោយមិនទុកពលរដ្ឋណាម្នាក់ចោលឡើយ»។ ក្នុងសង្គមមួយ យើងត្រូវតែខិតខំប្រឹងប្រែងដើម្បីការផ្លាស់ប្តូរនេះ និងធ្វើសកម្មដើម្បីគាំទ្រដល់សមាជិកអ្នកស្រឡាញ់ភេទដូចគ្នាក្នុងសហគមន៍របស់យើង។ បើទោះជាមានការវិ វឌ្ឍជាវិជ្ជមាននៃកិច្ចសហប្រតិបត្តិការរវាងក្រសួងនានា ជាមួយនឹងអង្គការសង្គមស៊ីវិលក្នុងការលើកកម្ពស់សិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នាក៏ដោយ ក៏នៅមានកិច្ចការជាច្រើនទៀត

ដែលត្រូវធ្វើដើម្បីធានាថាអ្នកស្រឡាញ់ភេទដូចគ្នាមានសិទ្ធិស្មើគ្នានៅក្នុងគ្រប់វិស័យ ទាំងសេដ្ឋកិច្ច សង្គម និង ជីវភាពនយោបាយ និងធានាថាគ្មានការផាត់អ្នកស្រលាញ់ភេទដូចគ្នាចេញពីវិស័យការងារនិងមានសិទ្ធិក្នុងការអនុវត្តសិទ្ធិមូលដ្ឋានរបស់ខ្លួន បើទោះជាពួកគេមាននិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ ឬ ការបង្ហាញនូវទំនោរយេនឌ័របែបណាក្តី។

នៅសប្តាហ៍នេះតំណាងរបស់អង្គការអនាគតយុវជនកម្ពុជាអាស៊ាននិងតំណាងនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជានឹងចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអន្តរជាតិអំពីបញ្ហារបស់អ្នកស្រឡាញ់ភេទដូចគ្នា ទាក់ទងទៅនឹងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រនៅទីក្រុងប៉ារីស។ កិច្ចប្រជុំនេះនឹងមានការចូលរួមពីតំណាងក្រសួងអប់រំ យុវជន និង កីឡា នៃប្រទេសកម្ពុជា ដែលនឹងមានការផ្លាស់ប្តូរបទពិសោធន៍ជាលក្ខណៈសកលនិងការស្វែងរកដំណោះស្រាយ ហើយនឹងទទួលបានគំនិតច្នៃប្រឌិតថ្មីៗដែលមានប្រយោជន៍សម្រាប់ការតស៊ូមតិរបស់ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា។

នេះគឺជាខួបទី១១ឆ្នាំ ដែលមានការប្រារព្ធទិវាមោទនភាព និងទិវាអន្តរជាតិប្រឆាំងការរើសអើងលើអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា។ ការដែលរំលេចនូវពាក្យស្លោកថា "ខ្ញុំគឺខ្ញុំ" គឺដើម្បីបង្ហាញអំពីផ្នត់គំនិតវិជ្ជមានរបស់អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជាក្នុងការទទួលយកនិងជាការប្រារព្ធដល់សិទ្ធិទាក់ទិននឹងនិន្នាការភេទនិងអត្តសញ្ញាយេនឌ័រ ឬការបង្ហាញនូវទំនោរយេនឌ័ររបស់ពួកគេ ព្រមទាំងអំពាវនាវដល់ពលរដ្ឋកម្ពុជាឱ្យទទួលស្គាល់និន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ ឬ ការបង្ហាញនូវទំនោរយេនឌ័ររបស់បុគ្គលគ្រប់រូប។

យើងខ្ញុំ ជាអង្គការសង្គមស៊ីវិលដែលមានរាយនាមខាងក្រោម មានជំហរជាឯកច្ឆន្ទស្នើឱ្យមានការទទួលយកនិងបញ្ជ្រាបការយល់ដឹងអំពីសិទ្ធិរបស់អ្នកស្រលាញ់ភេទដូចគ្នាទៅដល់អាជ្ញាធរ គ្រួសារ សាលារៀន កន្លែងការងារ និងសង្គមទាំងមូល។ យើងខ្ញុំសូមស្នើជាអនុសាសន៍ដូចខាងក្រោម ៖

**១. បញ្ឈប់ការរើសអើង ៖** បញ្ឈប់ការរើសអើងទៅលើអ្នកស្រឡាញ់ភេទដូចគ្នាដោយផ្អែកលើនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ ឬ ការបង្ហាញនូវទំនោររបស់យេនឌ័ររបស់ពួកគេ ទោះជានៅផ្ទះ សាលារៀន កន្លែងធ្វើការ មណ្ឌលថែរក្សាសុខភាព ឬ នៅតាមទីសាធារណៈផ្សេងៗក្តី។ ខណៈដែលការផ្លាស់ប្តូរច្បាប់ អាចនឹងត្រូវប្រើពេលវេលាយូរ ដូច្នេះក្រសួងពាក់ព័ន្ធអាចដាក់ចេញសារាចរណែនាំសម្រាប់អោយវិស័យផ្សេងៗអនុវត្ត។

**២. ការអប់រំ ៖** បញ្ជ្រាបដល់សិស្សនិស្សិត និងសាធារណជនទូទៅអំពីបញ្ហាអ្នកស្រឡាញ់ភេទដូចគ្នាដើម្បីបង្កើនការយល់ដឹង និងដាក់បញ្ចូលទៅក្នុងកម្មវិធីអប់រំ ដូចជា៖

ក) បញ្ចូលប្រធានបទស្តីពីនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ ឬការបង្ហាញនូវទំនោរយេនឌ័រក្នុងកម្មវិធីរបស់រដ្ឋ ឬ ឯកជន

ខ) បង្ហាញទិដ្ឋភាពប្រាកដនិយម និងភាពវិជ្ជមាននៃជីវិតអ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងប្រព័ន្ធផ្សព្វផ្សាយ។

**៣. ផ្តល់ភាពស្របច្បាប់ដល់អាពាហ៍ពិពាហ៍ភេទដូចគ្នា និងការទទួលយកកូនមកចិញ្ចឹម ៖** អនុញ្ញាតឱ្យអ្នកស្រលាញ់ភេទដូចគ្នាអាចរៀបការជាប្តី-ប្រពន្ធនឹងគ្នាបាន និងមានសិទ្ធិសុំកូនចិញ្ចឹម ដោយធានាឱ្យមានសមភាពកាន់តែប្រសើរ ក្នុងចំណោមប្រជាពលរដ្ឋកម្ពុជាដោយមិនគិតពីយេនឌ័រ។

**៤. ការដាក់បញ្ចូលអត្តសញ្ញាណយេនឌ័រក្នុងឯកសារច្បាប់ ៖** មានជម្រើសសម្រាប់អ្នកស្រលាញ់ភេទដូចគ្នាអាចប្តូរអត្តសញ្ញាណភេទរបស់ខ្លួន នៅក្នុងឯកសារច្បាប់ដូចជាអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន ដើម្បីអោយស្របជាមួយនឹងយេនឌ័រដែលពួកគេបានកំណត់អត្តសញ្ញាណលើខ្លួនឯងរួចហើយ។

ជំហានទាំងនេះនឹងធានាថាកម្ពុជាបន្តធ្វើការឆ្ពោះទៅរកសិទ្ធិស្មើភាពគ្នានិងកាន់តែមានយុត្តិធម៌សម្រាប់ពលរដ្ឋគ្រប់រូប និងជាសង្គមមួយមានការចូលរួមពីសំណាក់ពលរដ្ឋកាន់តែច្រើន។

**អង្គការសង្គមស៊ីវិលដែលគាំទ្រសេចក្តីថ្លែងការណ៍នេះ រួមមាន៖**

| ល.រ | នាមអង្គការសង្គមស៊ីវិល | នាមអ្នកចូលរួម | លេខទំនាក់ទំនង |
|---|---|---|---|
| ១ | *បណ្តាញចតុមុខ* | *លោក គង់ ប៊ុនថន* | ០៩២ ៤៤៥ ១៨៦ |
| ២ | *អង្គការអនាគតយុវជនកម្ពុជាអាស៊ាន* | *លោក ស្រ៊ុន ស្រ៊ន* | ០៩៣ ៦០០ ២៣៤ |
| ៣ | *មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា* | *លោក នួន ស៊ីដារ៉ា* | ០៩៧ ៩៦៦៦ ៥៦៦ |
| ៤ | *គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការសមាគមការពារសិទ្ធិមនុស្ស* | *លោក សួន ប៊ុនស័ក្តិ* | ០៩២ ៣៤៤ ៣៥៧ |
| ៥ | *អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ* | *លោកស្រី ណាលី ពីឡូក* | ០១២ ៨០៣ ៦៥០ |
| ៦ | *អង្គការ អេហ្វអេដអាយ៣៦០* | *លោក ហេង សាលី* | ០៧៧ ៧៨៧ ៦៩៦ |
| ៧ | *អង្គការខាណា* | *លោក ជួប សុខចំរើន* | ០៩២ ៦១៦ ៦៦៩ |
| ៨ | *មេឌា វន* | *លោក តុន គន្ធែល* | ០១២ ៧៣៧ ៦២៣ |
| ៩ | *អង្គការលីកាដូ កាណាដា* | *លោកស្រី លី រ៉ូប៊ីនស៊ុន* | ០១៧ ៧៩៩ ៧១៥ |
| ១០ | *អង្គការសុខភាពបុរសកម្ពុជា* | *លោក ម៉ៅ គឹមរុន* | ០១២ ៤០៤ ៦៦៩ |
| ១១ | *អង្គការសេវាសង្គមសុខភាពបុរស* | *លោក ដក បញ្ញា* | ០១៧ ៣៦៦ ៦៤៤ |

| | | | |
|---|---|---|---|
| ១២ | អង្គការមែក្រូវ៉េនបូ អន្តរជាតិ | លោក គង់ យ៉ារ៉ា | ០៧០ ៧៤១ ១៨៥ |
| ១៣ | អង្គការសហគមន៍ឥន្ទធនូកម្ពុជា | កញ្ញា ហេង ជ័យលាភី | ០៨១ ៧៨០ ០៦០ |
| ១៤ | សមាគមន៍រ៉ាក់ | លោក រ៉ា ជីវ័ន្ត | ០២៣ ៨៨៥ ១៣៥ |
| ១៥ | អេ រី បា | លោក អទ្រៀន អារើរី | ០១៦ ៣៨០ ១៦៣ |
| ១៦ | ហៀល ហ្គោដ ខូហ្វី | ចូហ្ស អាន់ដេល រីវើរ៉ា | ០៩៥ ៣៨០ ១៦៣ |
| ១៧ | មេត្តាហោស៍ | លោក នីកូលោស មេស្មើរហាម | ០១០ ៣១២ ៣៣៣ |
| ១៨ | មោទនភាពភ្នំពេញ | លោក អេម ប៊ី តុលា | ០៨៩ ៤៣៣ ៣៦៣ |
| ១៩ | រាម ប៊ូថាន រីស៊ត់ | លោក ដឹក ជី ហ្គ្រាហ្វ | ០១២ ៩៦៣ ៥៤៤ |
| ២០ | ស្លេស ហ៊ៃរ | លោក ឈូក សុភាព | ០១៦ ៩១៦ ២៦៣ |